អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**OFFICE OF THE CO-INVESTIGATING JUDGES**
**BUREAU DES CO-JUGES D'INSTRUCTION**

# អនុស្សរណៈ

ផ្ញើជូន៖ **អ្នកស៊ើបអង្កេតទាំងអស់ នៅ ក.ស.ច.ស**

កាលបរិច្ឆេទ៖ ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៥

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 30-Sep-2015, 15:33
CMS/CFO: Sann Rada

ពី៖ **ចៅក្រម Michael Bohlander សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

កម្មវត្ថុ៖ **សេចក្តីណែនាំស្តីពីការថតការស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី**

## សម្ងាត់

នៅថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២ សហចៅក្រមស៊ើបអង្កេត (“ស.ច.ស”) បានចេញអនុស្សរណៈណែនាំទៅអ្នកស៊ើបអង្កេតទាំងអស់នៅ ក.ស.ច.ស ថា លែងតម្រូវឲ្យថតយកសំឡេង ឬរូបភាពនៃការស្តាប់ចម្លើយសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីទៀតហើយ( “អនុស្សរណៈថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២”)[1]។

ខ្ញុំកត់សម្គាល់ថា អនុលោមតាមវិធានផ្ទៃក្នុង ២៥ និងដូចបានបញ្ជាក់ដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២[2] គឺមិនតម្រូវឲ្យថតយកសំឡេង ឬរូបភាពនៃការស្តាប់ចម្លើយសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីទេ។ ដូច្នេះ នៅក្នុងការចេញអនុស្សរណៈថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២ ស.ច.ស បានបំពេញកិច្ចយ៉ាងត្រឹមត្រូវដែលស្ថិតនៅក្នុងឆន្ទានុសិទ្ធិរបស់ខ្លួន។ ប៉ុន្តែ ខ្ញុំពេញចិត្តចំពោះការយល់ឃើញដែលថា ការថតយកសំឡេងនៃការស្តាប់ចម្លើយគឺជាការអនុវត្តល្អ ពីព្រោះថា ការធ្វើរបៀបនេះនាំឲ្យមានតម្លាភាព ដោយមិនប៉ះពាល់ដល់ប្រសិទ្ធផលនៅក្នុងកិច្ចស៊ើបសួររបស់តុលាការទេ។ បន្ទាប់ពីបានពិភាក្សាបញ្ហានេះជាមួយ

[1] សំណុំរឿង ០០៣ ឯកសារ D61 *សេចក្តីណែនាំស្តីពីការស្តាប់ចម្លើយសាក្សី* ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២។

[2] សំណុំរឿង ០០២ ឯកសារ E142/3 *សេចក្តីសម្រេចលើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៣៥នៃវិធានផ្ទៃក្នុងពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្តាប់ចម្លើយសាក្សី របស់ ក.ស.ច.ស* ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ កថាខណ្ឌ ៦។

សហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង រួចមក ខ្ញុំបានសម្រេចបន្តការអនុវត្តថតយកសំឡេង នៃការស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី។

អាស្រ័យហេតុនេះ ចាប់ពីថ្ងៃនេះតទៅ ណែនាំឲ្យ អ្នកស៊ើបអង្កេតទាំងអស់នៅ ក.ស.ច.ស ត្រូវថតយកសំឡេងនៃការស្តាប់ចម្លើយទាំងអស់នៅក្នុងសំណុំរឿង ០០៣។

**Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co-Investigating Judge**
**Co-juge d'instruction international**